# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Dec-2011, 10:57
CMS/CFO: Ly Bunloung

## សេចក្ដីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី សរ សុវ៉ាន

មេធាវី Jacques VERGÈS

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូវ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ុច ស្រីផាត់

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ជូនភាគីនូវបញ្ជីឈ្មោះសាក្សី ដែលនឹងត្រូវកោះហៅឱ្យមកបង្ហាញខ្លួន នៅក្នុងសវនាការដំណាក់កាលដំបូងទាក់ទងនឹងការពិនិត្យភ័ស្តុតាង ដែលត្រូវប្រព្រឹត្តទៅនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១ ក្រោយពេលបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់។ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីបញ្ជាក់អំពីឯកសារពាក់ព័ន្ធនឹងការធ្វើសក្ខីកម្មដំណាក់កាលដំបូងនេះ ក្នុងចំណោមបញ្ជីរបស់ខ្លួនកាលពីមុន[1]។

២. កាលពីថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជាការឆ្លើយតបទៅនឹងការបង្គាប់នេះ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ជីមួយដូចគ្នាទៅនឹងបញ្ជីនានាដែលខ្លួនបានដាក់រួចមកហើយ សម្រាប់ការជំនុំជម្រះក្តីក្នុងដំណាក់កាលបួនដំបូង គឺមាន**<u>ជាង ១០.000 ឯកសារ</u>**[2]។ មេធាវីការពារក្តីលោក អៀង សារី បានដាក់នូវបញ្ជីដែលមាន ៣១[3] ឯកសារ រីឯមេធាវីការពារក្តីលោក លោកស្រី អៀង ធីរិទ្ធ បានដាក់នូវបញ្ជីដែលមាន ៨៨[4] ឯកសារ។ ចំណែកឯ លោក ខៀវ សំផន វិញ គាត់បានដាក់បញ្ជីដែលមាន ៨០ ឯកសារ[5]។

---

[1] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1 ("អនុស្សរណៈ") ទំព័រ ២ កថាខណ្ឌ ៣៖ "អង្គជំនុំជម្រះបង្គាប់ឱ្យភាគីបញ្ជាក់ឱ្យបានមុនថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថាតើឯកសារ និងវត្ថុតាងណាមួយនៅក្នុងបញ្ជីដំបូងរបស់ខ្លួន ដែលខ្លួនមានបំណងចង់ឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកទាក់ទងទៅនឹងឈ្មោះសាក្សី និងអ្នកជំនាញ ដែលអាចនឹងត្រូវបានកោះហៅក្នុងអំឡុងពេលសវនាការរយៈពេលបីសប្តាហ៍ដំបូង"។

[2] បញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងសវនាការនៅដំណាក់កាលដំបូង (ថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ("បញ្ជីរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ឯកសារ E131/1/2 ដែលក្នុងបញ្ជីនោះ ដើមបណ្តឹងរដ្ឋប្បវេណីយោងទៅលើឧបសម្ព័ន្ធសម្ងាត់របស់ខ្លួន ឯកសារ E109/2.1, E109/2.2 និង E109/2.3។

[3] បញ្ជីឯកសាររបស់ អៀង សារី សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/1/3 និងឧបសម្ព័ន្ធសាធារណៈ ឯកសារ E131/1/3.2។

[4] សេចក្តីចង្អុលបង្ហាញរបស់ អៀង ធីរិទ្ធ ទៅលើឯកសារពាក់ព័ន្ធនឹងការជំនុំជម្រះដំណាក់កាលដំបូង ("បញ្ជីរបស់អ្នកស្រី អៀង ធីរិទ្ធ") ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/1/5 និងឧបសម្ព័ន្ធសាធារណៈ ឯកសារ E131/1/5.1។

[5] ការចង្អុលបង្ហាញពាក់ព័ន្ធនឹងសាក្សី ព្រមទាំងឯកសារនានា សម្រាប់ដំណាក់កាលទីមួយនៃការជំនុំជម្រះដំបូង ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/1/6 និងឧបសម្ព័ន្ធសម្ងាត់ ឯកសារ E131/1/6.2។

៣. កាលពីថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក ខៀវ សំផន បានទទួលការជូនដំណឹងអំពីបញ្ជីរបស់សហព្រះរាជអាជ្ញា ដែលមាន **៩៧៨ ឯកសារ**[6]។

៤. នៅថ្ងៃនេះ[7] លោក ខៀវ សំផន សូមបង្ហាញនូវសេចក្ដីជំទាស់មិនទទួលយក តាម**ប្រភេទ**ឯកសារ ដោយសារតែ លោក ខៀវ សំផន និងក្រុមមេធាវីការពារក្ដី **មិនអាច**ពិនិត្យឯកសារ ជាង ១១.០០០ ក្នុងរយៈពេលតែដប់ថ្ងៃបានឡើយ ។

## I. ការមិនអាចពិនិត្យឯកសារជាង ១១.០០០ បានក្នុងរយៈពេលតែដប់ថ្ងៃ

៥. យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ "ក- មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ- មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ- ច្បាប់មិនអនុញ្ញាត ឬ ង- មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

៦. នៅក្នុងរឿងក្ដី ឌុច អង្គជំនុំជម្រះបានសម្រេចលើភាពអាចទទួលយកបាននៃភស្តុងតាង៖

> ដូច្នេះ ដើម្បីអាចយកមកប្រើជាភស្តុតាងបាន ឯកសារដែលមាននៅក្នុងសំណុំរឿងត្រូវបំពេញឲ្យបាននូវ**<u>បទដ្ឋានអប្បបរមានៃភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន</u>** ដែលចាំបាច់ ដើម្បីអាចដាក់ឯកសារទាំងនោះឲ្យដេញដោលបាន។ ក្រោយពេលឯកសារត្រូវបានបង្ហាញនៅក្នុងសវនាការ អង្គជំនុំជម្រះអាចថ្លឹងថ្លែងតម្លៃជាភស្តុតាង និងទម្ងន់នៃភស្តុតាងនេះ[8]។

---

[6] សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅ ក្នុងអំឡុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ ជាមួយនឹងឧបសម្ព័ន្ធ ក សម្ងាត់ ("បញ្ជីសហព្រះរាជអាជ្ញា") ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/1/4 និងឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ E131/1/4.1។

[7] អនុស្សរណៈ ទំព័រ ២៖ ភាគីទាំងអស់មានរយៈពេលដប់ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីបញ្ជីឯកសារ ដើម្បីដាក់សេចក្ដីជំទាស់ទៅនឹងឯកសារ វត្ថុតាង ប្រភេទនៃឯកសារ ឬវត្ថុតាងទាំងអស់នោះ។

[8] សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ E43/4 កថាខណ្ឌ ៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

(...) ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពី**យថាភាពនៃឯកសារ** អង្គជំនុំជម្រះចាំបាច់ ត្រូវមានឯកសារទាំងអស់ ដែលអាចមានទម្ងន់ទៅលើការសម្រេចរបស់ខ្លួន[9]។

៧. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីដាក់ឲ្យដេញដោលនៅក្នុងសវនាការ និងមុនពេលពិនិត្យតម្លៃជាភ័ស្តុតាងទាំងអស់ ឯកសារត្រូវបំពេញលក្ខណៈវិនិច្ឆ័យបី៖ យថាភាព ភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន។

៨. ក្រៅពីនេះទៀត អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួននឹង "ចាត់ការទៅលើសេចក្តីជំទាស់មិនទទួលយកមួយករណីម្តងៗ" [10]។

៩. ដើម្បីអាចពិនិត្យភាពអាចទទួលយកបាននៃភ័ស្តុតាងឲ្យបានត្រឹមត្រូវ អង្គជំនុំជម្រះបានស្នើសុំឲ្យភាគីផ្តល់បញ្ជីឯកសារជាប់ពាក់ព័ន្ធជាមួយសាក្សី ដែលអង្គជំនុំជម្រះគ្រោងនឹងស្តាប់ចម្លើយ ចាប់ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១[11]។

១០. ប៉ុន្តែ សហព្រះរាជអាជ្ញា ដែលបានដាក់បញ្ចូលក្នុងសំណុំរឿងនូវបញ្ជីឯកសារ ៩៧៨ ហើយដើមបណ្តឹងរដ្ឋប្បវេណី ដែលបានសម្រេចចិត្តដាក់ឯកសារទាំងស្រុងដែលបានដាក់រួចមកហើយ (ត្រូវជាជាង ១០.០០០ ឯកសារ) មិនបានយកចិត្តទុកដាក់ដោយចេតនាទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះនោះទេ។

១១. យោងតាមវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

---

[9] សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភ័ស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ឯកសារ E5/10/2 កថាខណ្ឌ ៨ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[10] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E74 ទំព័រ ៤។

[11] អនុស្សរណៈ ទំព័រ ១។

១២. ផ្ទុយទៅវិញ ស្ថានភាពបច្ចុប្បន្នបង្ហាញនូវការរំលោភជាក់ស្តែងទៅលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយសារមូលហេតុបី។

១៣. ទីមួយ សព្វថ្ងៃនេះ លោក ខៀវ សំផន ត្រូវបានដកហូតសិទ្ធិក្នុងការរៀបចំការពារខ្លួន ដូចបានធានាដោយមាត្រា ៣៥(ខ)(ថ្មី) នៃស្តីច្បាប់ពីការបង្កើត អ.វ.ត.ក[12] ដែលមានខ្លឹមសារដូចគ្នាទៅនឹងមាត្រា ៦(៣)(ខ) នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[13]។ ដូច្នេះជនជាប់ចោទពិតជាមិនអាចពិនិត្យភាពអាចទទួលយកបាននៃឯកសារទាំង ១១.០០០ នេះ ក្នុងរយៈពេលតែដប់ថ្ងៃ ដូចបានកំណត់ដោយអង្គជំនុំជម្រះនោះទេ។

១៤. ទីពីរ លោក ខៀវ សំផន ត្រូវបានដកហូតសិទ្ធិក្នុងការទទួលបាននីតិវិធីចំពោះមុខ ដែល "តម្រូវឲ្យអយ្យការ ក៏ដូចជាមេធាវីការពារក្តី មានលទ្ធភាពក្នុងការដឹងឮពីសេចក្តីសង្កេត ឬភ័ស្តុតាង ដែលដាក់ដោយភាគីម្ខាងទៀត និងជជែកពិភាក្សាទៅលើសេចក្តីសង្កេត ឬភ័ស្តុតាងនោះ" [14]។

១៥. ទីបី លោក ខៀវ សំផន ត្រូវបានរុញច្រានឲ្យស្ថិតនៅក្នុងស្ថានភាពចាញ់ប្រៀបសហព្រះរាជអាជ្ញាយ៉ាងច្បាស់ក្រឡែត។ នេះជាការរំលោភលើគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី ដែលជាផ្នែកមួយនៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[15]។

---

[12] មាត្រា ៣៥(ថ្មី)៖ "(...) នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវ (...) ខ) មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន"។

[13] មាត្រា ៦(៣)៖ "រាល់ជនជាប់ចោទមានសិទ្ធិទទួលបានជាអាទិ៍នូវ (...) ខ) ពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន"។

[14] រឿងក្តី *Öcalan តទល់នឹង Turquie* បណ្តឹង ៤៦២២១/៩៩ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ១៤៦។

[15] រឿងក្តី *Dombo Beheer B.V. តទល់នឹងប្រទេសហូឡង់* បណ្តឹង ១៤៤៤៨/៨៨ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៣ ; រឿងក្តី *Foucher តទល់នឹងប្រទេសបារាំង* បណ្តឹង ២២២០៩/៩៣ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣៤ ; រឿងក្តី *Ben Naceur តទល់នឹងប្រទេសបារាំង* បណ្តឹង ៦៣៨៧៩/០០ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១ ; រឿងក្តី *Gacon តទល់នឹងប្រទេសបារាំង* បណ្តឹង ១០៩២/០៤ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៣១៖ "គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី ដែលជាធាតុផ្សំនៃសញ្ញាណទូលំទូលាយនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ តម្រូវឲ្យភាគីនីមួយៗមានលទ្ធភាពសមស្របក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ក្នុងលក្ខខណ្ឌដែលមិនធ្វើឲ្យខ្លួនស្ថិតក្នុងស្ថានភាពចាញ់ប្រៀបគូបដិបក្ខ"។

១៦. ជាការពិត សាក្សីដំបូងដែលអង្គជំនុំជម្រះកោះហៅឱ្យចូលមកបង្ហាញខ្លួន សុទ្ធតែជាសាក្សីស្នើឡើង ដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី គឺគ្មានសាក្សីរបស់លោក ខៀវ សំផន ទាល់តែសោះ[16]។ ក៏ប៉ុន្តែ ច្បាស់ណាស់ លោក ខៀវ សំផន ពិតជាមិនអាចពិនិត្យឯកសារទាំង ៩៧៨ របស់សហព្រះរាជអាជ្ញា និងឯកសារទាំង ១០.០០០ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីកំណត់ថាតើឯកសារណាខ្លះពាក់ព័ន្ធនឹងសាក្សីដំបូងៗទាំងនេះ ជាការត្រៀមរៀបចំសម្រាប់ការសួរសំណួរ។

១៧. ក្នុងកាលៈទេសៈបែបនេះ៖

- លោក ខៀវ សំផន សូមជំទាស់ទៅនឹងឯកសារទាំងឡាយណា ដែលមិនមានភាពជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបុគ្គលដែលត្រូវចូលមកបង្ហាញខ្លួននៅចំពោះអង្គជំនុំជម្រះសាលាដំបូង ចាប់ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។
- លោក ខៀវ សំផន គ្មានជម្រើសណាផ្សេងទៀតក្រៅពីបង្ហាញការជំទាស់ជាទូទៅទៅលើប្រភេទឯកសារមួយចំនួន ដែលមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត។

## II. ភាពមិនអាចទទួលយកបាននៃប្រភេទឯកសារមួយចំនួន

### ១. __ចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម__

១៨. មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម[17] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[18] និងវិធាន ២១(៣) នៃវិធានផ្ទៃក្នុង ហាមឃាត់ការប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាព ដែលទទួលបានដោយការធ្វើទារុណកកម្ម[19]។

---

[16] អនុស្សរណៈ ឧបសម្ព័ន្ធ ខ សម្ងាត់ ឯកសារ E131/1.2។

[17] មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប៖ "រដ្ឋភាគីត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាង ក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម"។

[18] មាត្រា ៣២១៖ "ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ"។

[19] វិធាន ២១(៣)៖ "គ្មានទម្រង់ណាមួយនៃការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬការគំរាមកំហែង ត្រូវបានយកទៅអនុវត្ត ក្នុងពេលធ្វើសម្ភាសន៍ ចំពោះអ្នកដែលត្រូវបានសួរយកចម្លើយ ឬអ្នកដទៃទៀតឡើយ។ ប្រសិនបើទម្រង់ណាមួយនៃស្ថានភាពទាំង

១៩. ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម គឺជាអង្គហេតុមិនអាចទទួលយកបានទេ (...) ហើយមិនអាចចាត់ទុកថាជាការពិតនោះទេ" [20]។

២០. យោងតាមវិធាន ៨៧(៤)(ឃ) ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះប្រកាសមិនទទួលយកភ័ស្តុតាង បើច្បាប់បានហាមឃាត់ លោក ខៀវ សំផន ស្នើសុំឲ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងប្រកាសបដិសេធឯកសារចម្លើយសារភាពទាំងអស់ ដែលទទួលបានដោយការធ្វើទារុណកម្ម។

២១. ម្យ៉ាងវិញទៀត លោក ខៀវ សំផន សូមរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកបទចោទ និងសម្រេចថា "អង្គហេតុជាមូលដ្ឋាននៃបទចោទ ដែលនឹងត្រូវពិនិត្យនៅក្នុងការជំនុំជម្រះក្តីដំណាក់កាលដំបូង មិនពាក់ព័ន្ធនឹង (...) មន្ទីរសន្តិសុខ ឬទីតាំងសម្លាប់មនុស្សណាមួយឡើយ"[21]។ ដូច្នេះ អង្គជំនុំជម្រះក៏ត្រូវដកឯកសារពាក់ព័ន្ធនឹងមន្ទីរស-២១ ចេញផងដែរ ដោយហេតុថាឯកសារទាំងនេះគ្មានភាពជាប់ពាក់ព័ន្ធ យោងតាមវិធាន ៨៧(៣)(ក)។

## ២. <u>កំណត់ហេតុស្តាប់ចម្លើយសាក្សី</u>

២២. នៅក្នុងសេចក្តីសង្កេត ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១[22] លោក ខៀវ សំផន បានរំឭកដល់អង្គជំនុំជម្រះថា គោលការណ៍ជាធរមាននៅ អ.វ.ត.ក គឺគោលការណ៍បង្ហាញខ្លួនរបស់សាក្សី ដើម្បីធ្វើការដេញដោលតទល់គ្នា។

---

នេះត្រូវបានប្រើប្រាស់ នោះចម្លើយ ឬកំណត់ហេតុមិនត្រូវចាត់ទុកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ"។

[20] រឿងក្តី ឌុច ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ D288/4.27.1, ERN 00337066 ទំព័រ ៧។

[21] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124 កថាខណ្ឌ ៩។

[22] សេចក្តីសង្កេតតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E96/4។

២៣. យោងតាមទឡ្ហីករណ៍ដែលបានលើកឡើងខាងលើ កំណត់ហេតុស្តាប់ចម្លើយសាក្សីមិនអាចទទួលយកបានទេ ប្រសិនបើគ្មានការសួរដេញដោលនោះ។ ដូច្នេះ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ត្រូវស្ថិតនៅក្នុងករណីពិសេស និងត្រូវគោរពលក្ខខណ្ឌតឹងរ៉ឹង។

## ៣. ឯកសារក្រោយហេតុការណ៍កើតឡើង

២៤. ភស្តុតាងសំដៅដល់មធ្យោបាយ ដែលប្រើប្រាស់សម្រាប់ជាតឹកតាង ឯកភាព សបញ្ជាក់ និងពិនិត្យផ្ទៀងផ្ទាត់[23]។ ភស្តុតាងត្រូវអនុញ្ញាតឲ្យចៅក្រមមានការជឿជាក់ដោយឥតស្សរចិត្ត និងសម្រេចលើបទចោទ។ តាមធម្មតា ភស្តុតាងគឺជាកំណត់ហេតុកត់ត្រា ឬកំណត់ហេតុស្តាប់ចម្លើយ ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ជាភស្តុតាងផ្អែកលើសក្ខីកម្ម ជាភស្តុតាងជាលាយលក្ខណ៍អក្សរ ជាវត្ថុតាង ឬជាចម្លើយសារភាព។

២៥. ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាបានកំណត់ "ភស្តុតាងពីរប្រភេទដែលមានភាពជាប់ពាក់ព័ន្ធនៅក្នុងនីតិវិធីតុលាការ ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម គឺភស្តុតាងសម្ភារៈ និងសក្ខីកម្ម" [24]។ ក្នុងចំណោមភស្តុតាងសម្ភារៈ ក្រុមអ្នកជំនាញបានរៀបរាប់ "អដ្ឋិធាតុ រចនាសម្ព័ន្ធ និងវត្ថុមេកានិច និងឯកសារ"[25]។ "ភស្តុតាងជាឯកសាររួមមានឯកសារផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលកំណត់អំពីតួនាទីរបស់បុគ្គលមួយចំនួន នៅក្នុងបទល្មើសធ្ងន់ធ្ងរប្រឆាំងនឹងសិទ្ធិមនុស្ស" [26]។

២៦. លោក ខៀវ សំផន សូមជំទាស់ទៅនឹងការទទួលយកឯកសារក្រោយហេតុការណ៍កើតឡើង ពីព្រោះឯកសារទាំងនេះមិនមែនជាភស្តុតាងនោះទេ គឺសុទ្ធតែជាឯកសារសាធារណៈសម្រាប់ផ្តល់ព័ត៌មាន

---

[23] សៀវភៅនិពន្ធដោយ Gérard CORNU មានចំណងជើងថា វាក្យស័ព្ទច្បាប់ បោះពុម្ពផ្សាយដោយ Presses Universitaires de France បោះពុម្ពលើកទី ៨ ឆ្នាំ ២០០៧ និយមន័យនៃពាក្យ "ភស្តុតាង"។

[24] លិខិតរួមរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ឧបសម្ព័ន្ធ៖ របាយការណ៍ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បង្កើតឡើងតាមសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៣៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៩ ឯកសារ S/1999/231 កថាខណ្ឌ ៥១។

[25] ដូចខាងលើ កថាខណ្ឌ ៥២។

[26] ដូចខាងលើ កថាខណ្ឌ ៥៣។

ទៅវិញទេ និងពីព្រោះឯកសារទាំងនេះមិនបានបំពេញលក្ខណៈវិនិច្ឆ័យយថាភាព ភាពគួរឱ្យជឿជាក់បាន និងភាពជាប់ពាក់ព័ន្ធ ដូចអង្គជំនុំជម្រះបានតម្រូវឡើយ។ ច្បាស់ជាងនេះទៅទៀត លោក ខៀវ សំផន និយាយសំដៅដល់ឯកសារបីប្រភេទ គឺសៀវភៅ របាយការណ៍វិភាគ និងខ្សែភាពយន្តឯកសារ[27]។

## ➢ សៀវភៅ

២៧. សៀវភៅបែបប្រវត្តិសាស្ត្រ ឬប្រលោមលោកនិយាយពីសម័យខ្មែរក្រហម មិនអាចត្រូវបានចាត់ទុកថាជាភ័ស្តុតាងឡើយ។ ក្នុងគោលដៅនេះ សហចៅក្រមស៊ើបអង្កេតបានរំឭកថា "សៀវភៅគឺជាឯកសារសាធារណៈ ដែលមិនចាំបាច់ដាច់ខាតត្រូវតែដាក់ចូលក្នុងសំណុំរឿងនោះទេ"[28]។

២៨. ជាដំបូង នៅពេលធ្វើការកំណត់ភាពអាចទទួលយកបាននៃឯកសារមួយថាជាភ័ស្តុតាង លក្ខខណ្ឌតម្រូវរបស់តុលាការមានកម្រិតខ្ពស់ខ្លាំងជាងលក្ខខណ្ឌតម្រូវ ដែលអ្នកនិពន្ធឯកសារបោះពុម្ពផ្សាយផ្ទាល់ខ្លួនត្រូវបំពេញ[29]។

២៩. ម្យ៉ាងវិញទៀត អ្នកនិពន្ធសៀវភៅបង្ហាញអំពីទស្សនៈ ការយល់ឃើញផ្ទាល់ខ្លួនទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ[30]។ អាស្រ័យហេតុនេះ ខ្លឹមសារនៃឯកសារទាំងនេះផិតដាមទៅដោយសេចក្ដីលម្អៀងផ្ទាល់ខ្លួន ដោយមិនអាចប្រកែកបាន។

---

[27] ដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងដាក់បញ្ចូលខ្សែភាពយន្តឯកសារ។

[28] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការដាក់ភ័ស្តុតាងបន្ថែមក្នុងសំណុំរឿង ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ឯកសារ D313/1 កថាខណ្ឌ ២។

[29] អត្ថបទនិពន្ធដោយ Steve HEDER ចុះក្នុងកាសែត *ខឺ ភែមបូឌា ដេលី* ចេញផ្សាយថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៩ ឯកសារ D312.2.12, ERN 00752640៖ "បទដ្ឋានភស្តុតាងសម្រាប់ការជំនុំជម្រះក្ដីមួយមានលក្ខណៈខ្ពស់ជាងបទដ្ឋានភ័ស្តុតាងសម្រាប់សារព័ត៌មាន ឬសៀវភៅប្រវត្តិសាស្ត្រមួយឆ្ងាយណាស់"។

[30] មានឧទាហរណ៍ជាច្រើនលើភាពផ្ទុយគ្នារវាងអ្នកនិពន្ធដែលបានសរសេរពីរបបកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ លោក Benedict F. KIERNAN បានរិះគន់សារព័ត៌មាន ញូយ៉ក ថែមស៍ ដែលបានចាត់ទុកលោក Philip Short ជា "អ្នកស្រាវជ្រាវទៀងត្រង់" និងយល់ឃើញថា "ប្រជាជនកម្ពុជាប្រហែលជាមិនអាចទទួលស្គាល់ប្រទេសរបស់ខ្លួន នៅក្នុងសៀវភៅនេះនោះទេ [Anatomie d'un cauchemar]" អ្នកនិពន្ធ Ben KIERNAN, « The Cambodian genocide and Imperial Culture », *in 90*

៣០. ជាចុងក្រោយ ការប្រកាសទទួលយកសៀវភៅទាំងអស់ជាភ័ស្តុតាង នឹងនាំឱ្យដល់ស្ថានភាពហួសហេតុ ពីព្រោះ ជាញឹកញាប់ណាស់ ឯកសារគាំទ្រដល់ទស្សនៈដែលសរសេរដោយអ្នកនិពន្ធមិនអាចទទួលយកបានទេ ដោយហេតុថាវាជាខ្លឹមសារនៃចម្លើយសារភាព ដែលទទួលបានដោយការធ្វើទារុណកម្ម ឬដោយហេតុថា គេមិនអាចកំណត់អត្តសញ្ញាណសាក្សីបាន[31]។

➢ **របាយការណ៍វិភាគ**

៣១. ការជំទាស់ដូចគ្នាអនុវត្តចំពោះរបាយការណ៍វិភាគ។ ជាការពិត ការវិភាគភ័ស្តុតាងត្រូវបានធ្វើឡើងដោយចៅក្រមនៃអង្គជំនុំជម្រះ គឺមិនមែនដោយ "អ្នកជំនាញ" ណាមួយឡើយ។ លោក ខៀវ សំផន សូមរំឭកថា ចំពោះរបាយការណ៍មួយក្នុងចំណោមរបាយការណ៍ទាំងបី ដែលសហព្រះរាជអាជ្ញា

---

*Years of Denial* ជាការបោះពុម្ពផ្សាយពិសេសរបស់សារព័ត៌មានប្រចាំថ្ងៃ Aztag (ទីក្រុងបេរូត) និងសារព័ត៌មានប្រចាំថ្ងៃអាកម៉េនី (វដ្តបូស្តុន) ខែ មេសា ឆ្នាំ ២០០៥ ដើម្បីរំឭកខួបលើកទី ៩០ នៃអំពើប្រល័យពូជសាសន៍ជនជាតិអាកម៉េនី ឆ្នាំ១៩១៥ (ទំព័រ ២០-២១)។ លោក François PONCHAUD បានប្រកាសប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា "មានសង្គ្រាមស្លាប់ប៉ាកកាវាងលោក Steve Heder លោក Noam Chomsky និងរូបលោកផ្ទាល់ ពាក់ព័ន្ធនឹងការបកស្រាយអត្ថបទ [ខ្មែរក្រហម]", កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D133 ទំព័រ ៣។ Gareth PORTER បានប្រកាសថា៖ "ក្នុងការពិភាក្សា *កម្ពុជា៖ ភាពអត់ឃ្លាន និងបដិវត្តន៍* Shawcross រំលោភម្តងហើយម្តងទៀតទៅលើសមធម៌បញ្ញា តាមមធ្យោបាយដែលចោទជាបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងវិធីសាស្ត្រទូទៅរបស់គាត់ចំពោះបញ្ហា" "ការផ្លាស់ប្តូរយោបល់ គ្នាអំពីប្រទេសកម្ពុជា" នៅក្នុង *The New York Review of Books* ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៨។ ក្នុងជំពូក ២ នៃសៀវភៅមានចំណងជើងថា *កម្ពុជា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៨២* ឯកសារ D222/1.17 លោក Michael VICKERY បានគូសបញ្ជាក់អំពីបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងឯកសារសំអាងតាមផ្លូវច្បាប់ និងបញ្ហាភ័ស្តុតាង។ គាត់បាននិយាយពី "ភាពលម្អៀងរបស់លោក Ponchaud" (ទំព័រ ៤៨) និង "ភាពលម្អៀង និងការសម្រិតសម្រាំង ស្តែងឱ្យឃើញច្បាស់បំផុត នៅក្នុងសៀវភៅរបស់ Barron និង Paul" (ទំព័រ ៤៦)។

[31] ក្នុងសំណុំរឿង ឌុច អង្គជំនុំជម្រះបានសម្រេចបដិសេធសក្ខីកម្មធ្វើឡើងដោយសាក្សីដែលបានស្លាប់ មុនពេលដែលខ្លួនត្រូវបានសហចៅក្រមស៊ើបអង្កេតសម្ភាសន៍ឡើងវិញ ហើយដែលសម្រាប់សក្ខីកម្មទាំងនោះ ទាំងសាក្សី ទាំងអ្នកបកប្រែ មិនបានស្បថឡើយ៖ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈ ដែលមាននៅក្នុងសំណុំរឿងធ្វើជាភ័ស្តុតាង ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ E43/4 កថាខណ្ឌ ១៦។ នៅក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានព្យាយាមសុំកាសែតថតសម្លេង និងឯកសារច្បាប់ដើមពីអ្នកនិពន្ធមួយចំនួន។ ឧទាហរណ៍ សូមមើល៖ លិខិតរបស់សហចៅក្រមស៊ើបអង្កេត៖ សំណើសុំព័ត៌មានទាក់ទងនឹងភ័ស្តុតាង ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D287 ; លិខិតរបស់សហចៅក្រមស៊ើបអង្កេត៖ សំណើសុំព័ត៌មានទាក់ទងនឹងភស្តុតាង ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D269/9។

មានបំណងដាក់ជាភ័ស្តុតាង (ឯកសារ ៧០ នៃឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា) លោក ខៀវ សំផន បានស្នើសុំយ៉ាងត្រឹមត្រូវឱ្យសហចៅក្រមស៊ើបអង្កេតដាក់បញ្ចូលទៅក្នុងសំណុំរឿង និងបកប្រែឯកសារទាំងអស់ដែលអ្នកនិពន្ធបានយោងដល់[32]។ ប៉ុន្តែ សំណើនេះត្រូវបានសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បដិសេធចោល[33]។ ដោយសារតែមិនអាចទទួលបានប្រភពដែលប្រើប្រាស់ដោយអ្នកសរសេររបាយការណ៍ លោក ខៀវ សំផន សូមជំទាស់ទៅនឹងការដាក់បញ្ចូលរបាយការណ៍ទាំងនេះជាភ័ស្តុតាង។

៣២. ម្យ៉ាងវិញទៀត របាយការណ៍វិភាគគ្មានភាពជាប់ពាក់ព័ន្ធ នៅក្នុងដំណាក់កាលនេះនៃការជំនុំជម្រះ ហើយនឹងអាចដាក់ចូលបាន តែប្រសិនបើម្ចាស់របាយការណ៍ទាំងនេះត្រូវបានកោះហៅឱ្យចូលមកបង្ហាញខ្លួន ដើម្បីដេញដោលតទល់គ្នា។ នៅក្នុងរឿងក្តី *Lubanga* តុលាការព្រហ្មទណ្ឌអន្តរជាតិ បានជំទាស់ទៅនឹងការទទួលយករបាយការណ៍មួយរបស់អ្នកជំនាញ ដោយសំអាងហេតុថារបាយការណ៍នេះមានភាពជាប់ពាក់ព័ន្ធតិចតួចបំផុត ហើយហានិភ័យនៃព្យសនកម្មទៅលើភាគីមានខ្ពស់ជាងតម្លៃជាភ័ស្តុតាង ដោយសារតែម្ចាស់របាយការណ៍មិនបានចូលមកបង្ហាញខ្លួន[34]។

➢ **ខ្សែភាពយន្តឯកសារ**

៣៣. បន្ថែមលើផលអាក្រក់ទាំងអស់ដែលបានរៀបរាប់ពីខាងលើ ខ្សែភាពយន្តឯកសារខ្វះភាពគួរឱ្យជឿជាក់បាន ដោយសារតែខ្សែភាពយន្តឯកសារសម្បូរទៅដោយមហិច្ឆតាសិល្បៈ ឬបច្ចេកទេសថតដែលធ្វើឱ្យសមិទ្ធករសម្របខ្លឹមសារនៃស្នាដៃរបស់ខ្លួនទៅនឹងលក្ខខណ្ឌកំហិតខាងក្រៅ។

---

32 សំណើសុំដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងសកម្មភាពដ៏ពិតប្រាកដរបស់លោក ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D370 កថាខណ្ឌ ៧។

33 ដីកាសម្រេចស្តីពី "សំណើសុំដាក់បញ្ចូលឯកសារពាក់ព័ន្ធដល់សកម្មភាពជាក់ស្តែងរបស់ ខៀវ សំផន" ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D370/1។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន" ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D370/2/11។

34 រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Lubanga* សំណុំរឿង ICC-01/04-01/06 សេចក្តីសម្រេចលើសំណើសុំទទួលយកជាភ័ស្តុតាងនូវរបាយការណ៍ស្តាពររបស់ក្រុមអ្នកជំនាញស្តីពីការធ្វើអាជីវកម្មធនធានធម្មជាតិខុសច្បាប់ និងទម្រង់ផ្សេងទៀតនៃរោគទ្រព្យរបស់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៤។

៣៤. ដូច្នេះ លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះប្រកាសបដិសេធឯកសារក្រោយហេតុការណ៍កើតឡើងទាំងអស់ ដោយសារតែឯកសារទាំងនេះមិនមែនជាភ័ស្តុតាង និងមិនអាចចាត់ទុកថាគួរឲ្យជឿជាក់បានឡើយ។

## ៤. អត្ថបទសារព័ត៌មាន

៣៥. នៅចំពោះមុខតុលាការពិសេស អត្ថបទសារព័ត៌មានមិនត្រូវបានចាត់ទុកជាភ័ស្តុតាងគួរឲ្យជឿជាក់បានទេ។ ជាធម្មតា អត្ថបទទាំងនេះត្រូវបានទទួលយក នៅពេលត្រូវបានសរសេរពេលកំពុងកើតហេតុការណ៍ និងគាំទ្រ ព័ត៌មានដែលផ្តល់ដោយភ័ស្តុតាងផ្សេងទៀត ហើយបញ្ជាក់អះអាងថាអង្គហេតុទាំងអស់ស្ថិតនៅក្នុងវិស័យសាធារណៈ[35]។ ក្រៅពីនេះទៀត តម្លៃជាភ័ស្តុតាងរបស់អត្ថបទសារព័ត៌មានត្រូវបានពិនិត្យមើលឡើងវិញ[36] ឬវិនិច្ឆ័យថាមានកម្រិតទាបជាងឥទ្ធិពលអាក្រក់របស់វាទៅលើភាពយុត្តិធម៌នៃនីតិវិធី។

៣៦. ជាឧទាហរណ៍ សូមរំឮកថា នៅពេលទទួលពាក្យបណ្តឹងដឹតចិត្តចៅក្រម Marcel LEMONDE របស់លោក ខៀវ សំផន អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានសន្និដ្ឋានថា "សេចក្តីថ្លែងការណ៍របស់ចៅក្រម Marcel LEMONDE <u>ដូចបានដកស្រង់ដោយអ្នកសារព័ត៌មាន មិនមែនជាភ័ស្តុតាងគួរឲ្យជឿជាក់បាននោះទេ</u> (...)"[37]។

៣៧. ក្នុងករណីនេះ លោក ខៀវ សំផន សូមជំទាស់ទៅនឹងការទទួលយកសេចក្តីថ្លែងការណ៍ជាមុនរបស់ជនជាប់ចោទទាំងឡាយ និងបុគ្គលដទៃទៀត ដែលចុះផ្សាយដោយសារព័ត៌មាន និងគ្មានការថតសម្លេង។

---

[35] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Radoslav Brdanin* សំណុំរឿង IT-99-36-T សាលក្រម ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៣។

[36] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Dario Kordic and Mario Cerkez* សំណុំរឿង IT-95-14/2-T កំណត់ហេតុនៃសវនាការសាធារណៈ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ទំព័រ ១៦៥២១។

[37] សាលដីកាលើបណ្តឹងដិតចិត្តរបស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel LEMONDE ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ ៧ កថាខណ្ឌ ៣០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៣៨. ការគោរពគោលការណ៍ចំពោះមុខតម្រូវឱ្យជនជាប់ចោទតទល់គ្នា ជាស្វ័យប្រវត្តិ ជាមួយអ្នកសារព័ត៌មានដែលជាម្ចាស់អត្ថបទ ប៉ុន្តែ អ្នកសារព័ត៌មានមិនត្រូវបានតម្រូវឱ្យបង្ហាញប្រភពឡើយ។ ដូច្នេះ ការការពារការសម្ងាត់នៃប្រភពរបស់អ្នកសារព័ត៌មានធ្វើឱ្យមិនអាចដេញដោលតទល់បាន។ អាស្រ័យហេតុនេះ ទោះបីជាអត្ថបទសារព័ត៌មានខ្លះអាចមានប្រយោជន៍ នៅក្នុងដំណាក់កាលស៊ើបអង្កេត ជាប្រទីបបំភ្លឺចៅក្រមអំពីបរិបទទូទៅនៃអង្គហេតុក៏ដោយ ក៏អត្ថបទទាំងនេះគំរាមកំហែងដល់យុត្តិធម៌នៃនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយមិនអាចប្រកាសទទួលយកជាភ័ស្តុតាងបានឡើយ។

## ៥. ឯកសារដែលមេធាវីការពារក្តីមិនទទួលបាន

៣៩. លោក ខៀវ សំផន សូមជំទាស់ ប្រសិនបើអង្គជំនុំជម្រះប្រកាសទទួលយកឯកសារទាំងឡាយណាដែលខ្លួននៅតែមិនទាន់ទទួលបាន ដោយរំលោភទៅនឹងសិទ្ធិក្នុងការរៀបចំការពារខ្លួន នៅខណៈដែលសវនាការលើអង្គសេចក្តីនឹងបើកក្នុងពេលមួយសប្តាហ៍ទៀតនេះ។

### ➢ ឯកសារដែលត្រូវបានចាត់ថ្នាក់សម្ងាត់បំផុត

៤០. កាលពីថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ លោក ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យខ្លួនទទួលបានឯកសារសម្ងាត់បំផុត ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់នៅក្នុងបញ្ជីឯកសារ ហើយដែលមេធាវីការពារក្តីមិនមានសិទ្ធិពិគ្រោះ និងស្គាល់តែចំណងជើងទូទៅប៉ុណ្ណោះ[38]។

### ➢ ឯកសារក្រៅសំណុំរឿង និងមិនបានផ្តល់ជូនមេធាវីការពារក្តី

[38] យោបល់ទាក់ទិននឹងសំណើរបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E118/3។

៤១. លើសពីនេះទៀត ឧបសម្ព័ន្ធ ក ដែលបង្ហាញដោយសហព្រះរាជអាជ្ញា[39] បញ្ជីដែលដាក់ដោយដើមបណ្ដឹងរដ្ឋប្បវេណី[40] និងបញ្ជីដែលដាក់ដោយមេធាវីការពារក្ដីលោកស្រី អៀង សារី[41] មានឯកសារថ្មី ដែលមិនមាននៅក្នុងសំណុំរឿង និងមិនបានផ្ដល់ជូនភាគីផ្សេងទៀត។

➢ **ឯកសារមិនបកប្រែ**

៤២. ជាចុងក្រោយ នៅក្នុងចំណោមឯកសារជាង ១១.០០០ ដែលបានដាក់ ដោយជាន់ល្មើសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង មួយផ្នែកធំមិនមានជាភាសាបារាំង និងខ្មែរនោះទេ។ ស្ថានភាពដដែលៗនេះ ទោះបីជាមានសំណើជាច្រើនសុំឱ្យបកប្រែក៏ដោយ[42] រំលោភលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការបកប្រែ និងការជំនុំជម្រះក្ដីដោយយុត្តិធម៌។

៤៣. យើងមើលឃើញយ៉ាងច្បាស់ថា លោក ខៀវ សំផន មិនអាចពិនិត្យភាពអាចទទួលយកបាននៃឯកសារ ដែលត្រូវបានចាត់ថ្នាក់សម្ងាត់បំផុត មិនបានផ្ដល់ជូនមេធាវីការពារក្ដី និងមិនបានបកប្រែជាភាសាការងាររបស់មេធាវីការការពារ។

៤៤. លោក ខៀវ សំផន យល់ឃើញថា ការរឹតត្បិតបីត្រួតនេះរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងច្បាស់ជាងនេះទៅទៀត សិទ្ធិក្នុងការទទួលបានការបង្កលក្ខណៈចាំបាច់ដល់ការរៀបចំការពារខ្លួន និងសិទ្ធិក្នុងការពិនិត្យភ័ស្តុតាងដោះបន្ទុក និងដាក់បន្ទុក[43] ក៏ដូចជា

---

[39] បញ្ជីរបស់សហព្រះរាជអាជ្ញា ឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ E131/1/4.1។

[40] បញ្ជីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឧសម្ព័ន្ធសម្ងាត់ ឯកសារ E109/2.3។

[41] បញ្ជីរបស់អ្នកស្រី អៀង ធីរិទ្ធ ឧបសម្ព័ន្ធ ក សាធារណៈ ឯកសារ E131/1/5.1។

[42] បណ្ដឹងសុំមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D197 ; លិខិតរបស់លោក ខៀវ សំផន ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ A406 ; បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ឯកសារ D427/4/3 កថាខណ្ឌ ៦៩ ដល់កថាខណ្ឌ ៧៣ ; បណ្ដឹងឧបាត្តិហេតុដើម្បីផ្អាកភ្លាមៗ និងជាស្ថាពរនូវនីតិវិធីដែលធ្វើឡើងប្រឆាំងនឹងលោក ខៀវ សំផន ដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ សំណុំរឿង ០០២/២១.១០.២០១០-អវតក/អបជ (១៥) ឯកសារ ១, ERN 00616968-00617000 កថាខណ្ឌ ២៣ ដល់កថាខណ្ឌ ៣០ ; បញ្ជីឯកសារ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/29 កថាខណ្ឌ ១១ និងកថាខណ្ឌ ១២។

[43] មាត្រា ៣៥(ថ្មី)៖ "(...) នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិ (...) ខ) មានពេលវេលា និងលក្ខណៈ

រំលោភលើគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី។

៤៥. លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះប្រកាសបដិសេធឯកសារទាំងអស់ ដែលមេធាវីការពារក្តី មិនអាចទទួលបាន ក្នុងកាលវេលាសមស្រប។

## ៦. ឯកសារដែលប្រមែប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

៤៦. លោក ខៀវ សំផន បានជម្រាបអង្គជំនុំជម្រះរួចមកហើយអំពីការមន្ទិលសង្ស័យទៅលើយថាភាព និងឫសគល់នៃឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា[44]។

៤៧. ដូច្នេះ លោក ខៀវ សំផន សូមស្នើជាថ្មីម្តងទៀតឲ្យអង្គជំនុំជម្រះមានការប្រុងប្រយ័ត្នខ្ពស់ នៅពេលពិនិត្យភ័ស្តុតាងដែលប្រមែប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាពិសេស ត្រូវមានច្បាប់ដើមនៃឯកសារទាំងអស់ ធានាឲ្យបាននូវយថាភាពនៃឯកសារ និងតម្រូវជាស្វ័យប្រវត្តិឲ្យខ្លឹមសារនៃព័ត៌មានត្រូវបានគាំទ្រដោយភ័ស្តុតាងផ្សេងទៀត។

### អាស្រ័យហេតុនេះ

៤៨. លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ជំទាស់**ទៅនឹងការដាក់ឯកសារទាំងឡាយណា ដែលមិនជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងបុគ្គលដែលត្រូវកោះហៅឲ្យចូលមកបង្ហាញខ្លួន ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១។
- **ប្រកាស**បដិសេធឯកសារចម្លើយសារភាពទាំងអស់ ដែលទទួលបានដោយការធ្វើទារុណកម្ម។
- **ប្រកាស**បដិសេធកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលមិនត្រូវបានដាក់ឲ្យដេញដោលតទល់គ្នា លើកលែងតែក្នុងករណីពិសេស និងត្រូវគោរពលក្ខខណ្ឌតឹងរ៉ឹង។
- **ប្រកាស**បដិសេធឯកសាក្រោយហេតុការណ៍កើតឡើងទាំងអស់។

---

គ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន ង) ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ”។

[44] បញ្ជីឯកសារ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/29 កថាខណ្ឌ ១៧ និងកថាខណ្ឌ ១៨។

- **ប្រកាស**បដិសេធអត្ថបទសារព័ត៌មានទាំងអស់។
- **ប្រកាស**បដិសេធឯកសារទាំងអស់ដែលមេធាវីការពារមិនទទួលបាន។
- **ធានា**ឲ្យបាននូវយថាភាពនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការគាំទ្រខ្លឹមសារនៃព័ត៌មានដោយភ័ស្តុតាងផ្សេងទៀត។

**រក្សាសិទ្ធិគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |